# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

លេខ ៣២៦ តកក.សរណ

# ប្រធានតុលាការកំពូល

**<u>ជម្រាបមក</u>**

## លោកប្រធានតុលាការគ្រប់ខេត្ត ក្រុង

**<u>កម្មវត្ថុ:</u>** អំពីការទទួលរក្សាទុកនូវប្រាក់ដែលជាវត្ថុតាងឬជាប្រាក់ធានាផ្សេងៗក្នុងរឿងក្ដីដែលមិនទាន់ចូលជាស្ថាពរ។

ខ្ញុំសូមជម្រាបលោកប្រធានតុលាការខេត្ត-ក្រុង ទាំងអស់ឱ្យបានជ្រាបថា កន្លងមកតុលាការកំពូលតែងបានសង្កេតឃើញមានបាតុភាពជាច្រើន កើតឡើងដោយសារការថែរក្សាទុកនូវប្រាក់តម្កល់ទុកធានារឿងក្ដី និងប្រាក់ដែលជាវត្ថុតាង ។

អាស្រ័យហេតុនេះ ចាប់ពីពេលនេះតទៅ ចៅក្រមទាំងអស់ត្រូវប្រគល់ប្រាក់ខាងលើ ដែលខ្លួនមានជូនលោកប្រធានតុលាការ ដោយមិនត្រូវរក្សាទុកផ្ទាល់ខ្លួនទេ ហើយលោកប្រធានតុលាការត្រូវចាត់ចែងបើកគណនីនៅធនាគារណាមួយ ដើម្បីតម្កល់ទុកនូវប្រាក់ទាំងនេះរង់ចាំអនុវត្តតាមសាលក្រម ឬសាលដីកាស្ថាពរ របស់តុលាការ ។

សូមលោកប្រធាន ទទួលនូវការរាប់អានពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០០៣

**ឌិត មុន្ទី**

<u>ចម្លងជូន</u>

-ក្រសួងយុត្តិធម៌

-សមាជិកឧត្តមក្រុមប្រឹក្សា នៃអង្គចៅក្រម

-ដើម្បីជាពត៌មាន